ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តពោធិ៍សាត់**
សំណុំរឿងរដ្ឋប្បវេណីលេខ ៣៦
ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣
សាលក្រមរដ្ឋប្បវេណីលេខ: ១៤១ (ក)
ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តពោធិ៍សាត់

សញ្ញាណរឿងក្តី: **ប្តឹងសុំលែងលះ**

កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង៣០នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង៣០នាទីរសៀល នៅសាលាដំបូងខេត្តពោធិ៍សាត់។

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ឋានៈប្រធានសាលាដំបូងខេត្តពោធិ៍សាត់

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ឋានៈក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់

**ដើមចោទ** ឈ្មោះ [redacted] មួយស៊ាង ភេទស្រី កើតឆ្នាំ១៩៩៨ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ [redacted]

ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ចុងចម្លើយ** ឈ្មោះ [redacted] ឈុនឡុង ភេទប្រុស កើតឆ្នាំ១៩៩៣ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិ [redacted]

ដែលមានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ**

**ក.ការទាមទាររបស់ដើមចោទ៖** ប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១- លែងលះពីចុងចម្លើយឈ្មោះ [redacted] ឈុនឡុង។

២- ផ្តល់អំណាចមេបា និងសិទ្ធិគ្រប់គ្រងលើកូនឈ្មោះ [redacted] ស៊ូលីន ភេទស្រី កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ មកអោយដើមចោទ។

៣- ប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ទៅអោយចុងចម្លើយ។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ឈុនឡុង ទទួលខុសត្រូវសងបំណុលចំនួន ៨៤០០០$ (ប្រាំបីម៉ឺនបួនពាន់ដុល្លារអាមេរិក) ដែលជំពាក់ធនាគា[redacted] បំណុលចំនួន ១៣០០០$ (មួយម៉ឺនបីពាន់ដុល្លារអាមេរិក) ជំពាក់ថ្លៃគ្រឿងសំណង់, បំណុលចំនួន ១៤៥០$ (មួយពាន់បួនរយហាសិបដុល្លារអាមេរិក) ជំពាក់ថ្លៃជាងជួសជុលឡានធំ, បំណុលចំនួន ៩៥០ $ (ប្រាំបួនរយហាសិបដុល្លារអាមេរិក) និងបំណុលតុងទីនចំនួន ៧៨០០$ (ប្រាំពីរពាន់ប្រាំបីរយដុល្លារអាមេរិក)។

៥- បង្គាប់ឲ្យចុងចម្លើយបង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនចំនួន ៤០០០០០រៀល (សែសិបម៉ឺនរៀល) ក្នុង១ខែ ជារៀងរាល់ខែ រហូតដល់កូនមានវ័យនីតិភាព។

៦- ប្រាក់ប្រដាប់ក្ដីតុលាការជាបន្ទុករបស់ចុងចម្លើយ។

**ខ.ការពន្យល់ត្រួសៗអំពីរឿងក្ដី**

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ របស់ដើមចោទគឺ កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយជាប្ដីប្រពន្ធតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្រប តាមច្បាប់។ ការរួមរស់ជាមួយគ្នាជាប្រពន្ធនោះ បង្កើតបានកូនស្រីម្នាក់ជាចំណងដៃអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិរួមមួយចំនួនផងដែរ។ ចាប់តាំងពីចាប់ដៃគ្នាជាប្ដីប្រពន្ធមក ដើមចោទរស់នៅពុំដែលមានសេចក្ដីសុខឡើយ ដោយត្រូវរ៉ែកពន់ និងទទួលខុសត្រូវលើរឿងគ្រប់បែបយ៉ាងទាំងអស់នៅក្នុងគ្រួសារ រួមទាំងការប្រកបរបរចិញ្ចឹមជីវិត ការមើលថែទាំកូន និងការដោះបំណុលគេតែម្នាក់ឯង ព្រោះចុងចម្លើយជាប្ដីពុំមានទំនួលខុសត្រូវទាល់តែសោះ ពុំបានផ្គត់ផ្គង់ ឬផ្ដល់ប្រាក់ឲ្យប្រពន្ធកូនឡើយ គិតតែពីដើរលេងមិនចូលផ្ទះ និងបង្ខិតបង្ខំអោយដើមចោទប្រឹងប្រែងរកស៊ីមុខរបរធំៗ ខិតខំរកលុយដើម្បីមុខមាត់របស់គេ និងក្រុមគ្រួសារគេ។ បន្ទាប់ពីរៀបការរួចភ្លាម ដោយមានការដាក់សម្ពាធពីខាងចុងចម្លើយ ដើមចោទបានយកប្រាក់ពីម្ដាយ និងខ្ចីគេខ្លះដើម្បីប្រកបមុខរបរលក់គ្រឿងសំណង់ និងឡានដឹកទំនិញសម្រាប់ជួល។ រយៈពេល ០៥ឆ្នាំនៃការរស់នៅជាមួយគ្នាកន្លងទៅនេះ គឺដើមចោទរស់នៅក្នុងសម្ពាធយ៉ាងធ្ងន់ធ្ងរ ប្រៀបដូចជាទាសីរបស់គេ បាត់បង់អស់សិទ្ធិសេរីភាពគ្រប់បែបយ៉ាង ស្គាល់តែទុក្ខព្រួយ និងភាពភ័យខ្លាចទទួលបានតែការប្រមាថមាក់ងាយ ការសម្លុតគម្រាមកំហែង និងការបំភិតបំភ័យដោយការសម្លែងអាវុធឥតឈប់ឈរ តែដើម្បីអនាគតកូនស្រីម្នាក់ ទើបដើមចោទសុខចិត្តអត់ធ្មត់ស៊ូទ្រាំ សម្របសម្រួលរហូតដល់៥ឆ្នាំនេះ។

**គ.ចំណុចវិវាទ៖** ដើមចោទឈ្មោះ [redacted] មួយស៊ាង សុំសិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ស៊ូលីន ភេទស្រី កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ប៉ុន្តែចុងចម្លើយមិនឯកភាពហើយស្នើសុំសិទ្ធអំណាចមេបាលើកូនស្រីនេះដែរ ។

**ឃ-ការអះអាងរបស់គូភាគី**

ដើមចោទឈ្មោះ [redacted] មួយស៊ាង ដែលមានលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្ញុំនៅតែរក្សាការទាមទារដូចមានក្នុងពាក្យបណ្ដឹងចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ កំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល ចុចជាបានការដដែលទាំងស្រុងដោយស្នើសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១.លែងលះពីចុងចម្លើយឈ្មោះ [redacted] ឈុនឡុង

២.ផ្ដល់អំណាចមេបា និងសិទ្ធិគ្រប់គ្រងលើកូនឈ្មោះ [redacted] ស៊ូលីន ភេទស្រី កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩

៣.ប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឲ្យទៅចុងចម្លើយ

៤.បង្គាប់ឲ្យចុងចម្លើយទទួលខុសត្រូវបំណុលរួមទាំងអស់

៥.បង្គាប់ឲ្យចុងចម្លើយបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ៤០ម៉ឺនរៀលក្នុង១ខែរហូតដល់កូនមានវ័យនីតិភាព។

៦.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ



Scanned with CamScanner

ដោយមូលហេតុ កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយជាប្តីប្រពន្ធតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របតាមច្បាប់។ ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធនោះបង្កើតបានកូនស្រីម្នាក់ កូននេះខ្ញុំសុំសិទ្ធិគ្រប់គ្រង ព្រោះខ្ញុំគិតថាខ្ញុំអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែកូន ខ្ញុំសន្យានិងធានាអះអាងថាអាចមើលថែកូនរបស់ខ្ញុំបានយ៉ាងល្អ ខ្ញុំនិងថែទាំកូនខ្ញុំដោយផ្ទាល់ដៃ ណាមួយកូនខ្ញុំនៅតូចអាយុទើបតែ៤ឆ្នាំទេ ដូច្នេះកូនត្រូវការមើលថែទាំពីម្តាយ។ ចាប់តាំងពីចាប់គ្នាជាប្តីប្រពន្ធមក នាងខ្ញុំរស់នៅពុំមានសេចក្តីសុខឡើយ ដោយត្រូវរែកពន់ និងទទួលខុសត្រូវលើរឿងគ្រប់បែបយ៉ាងនៅក្នុងគ្រួសារ ចុងចម្លើយជាប្តីពុំមានទំនួលខុសត្រូវទាល់តែសោះ ពុំបានផ្គត់ផ្គង់ ឬផ្តល់ប្រាក់ឲ្យប្រពន្ធកូនឡើយ គិតតែពីដើរលេងមិនចូលផ្ទះ និងបង្ខិតបង្ខំអោយនាងខ្ញុំប្រឹងប្រែងរកស៊ីមុខរបរធំៗ ខិតខំរកលុយដើម្បីមុខមាត់របស់គេ និងក្រុមគ្រួសារគេ។ បន្ទាប់ពីរៀបការរួចភ្លាម មានការដាក់សម្ពាធពីខាងចុងចម្លើយ នាងខ្ញុំបានយកប្រាក់ពីម្តាយខ្ញុំ និងខ្ចីគេខ្លះដើម្បីប្រកបមុខរបរលក់គ្រឿងសំណង់ និងឡានដឹកទំនិញសម្រាប់ជួល ហើយនាងខ្ញុំជានារីទន់ខ្សោយត្រូវលីរែកស៊ីម៉ង់រាល់ថ្ងៃតែម្នាក់ឯង ដោយចុងចម្លើយមិនដែលជួយទេ សុខចិត្តអង្គុយមើល និងបង្គាប់បញ្ជា។ រយៈពេល៥ឆ្នាំ នៃការរស់នៅជាមួយគ្នាកន្លងទៅនេះ គឺនាងខ្ញុំរស់នៅក្នុងសម្ពាធយ៉ាងធ្ងន់ធ្ងរប្រៀបដូចជាទាសីរបស់គេ បាត់បង់អស់សិទ្ធិសេរីភាពគ្រប់បែបយ៉ាង ស្គាល់តែទុក្ខព្រួយ និងភាពភ័យខ្លាចទទួលបានតែការប្រមាថម៉ាក់ងាយ ការសម្លុតគម្រាមកំហែង និងការបំភិតបំភ័យដោយការសម្លែងអាវុធឥតឈប់ឈរ តែដើម្បីអនាគតកូនស្រីម្នាក់ ទើបនាងខ្ញុំសុខចិត្តអត់ធ្មត់ស៊ូទ្រាំ សម្របសម្រួល រហូតដល់៥ឆ្នាំនេះ។ ទ្រព្យសម្បត្តិរួមដែលយើងខ្ញុំមានរួមគ្នាគឺមានដូចជា៖ ផ្ទះលំនៅដ្ឋាន១ល្វែង ទំហំ ១១៤១ ម៉ែត្រការ៉េ ស្ថិតនៅភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកានខេត្តពោធិ៍សាត់, ផ្ទះលំនៅដ្ឋាន១ល្វែង ទំហំ៥៩ម៉ែត្រការ៉េ ស្ថិតនៅភូមិគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ តម្លៃប្រហែល ៤០៨២៨$ (បួនម៉ឺនប្រាំបីរយម្ភៃប្រាំបីដុល្លារអាមេរិក), សម្ភារៈសំណង់សម្រាប់លក់មានតម្លៃសរុបប្រហែល៣ម៉ឺនដុល្លារអាមេរិក, រថយន្ត Pick Up ពីរបាំងម៉ាក  Nissan Navara ផលិតឆ្នាំ២០១៩ស្លាកលេខ កម្ពុជា LCL.1993 ០១គ្រឿង, រថយន្តធុនធំសម្រាប់ដឹកទំនិញចំនួន២គ្រឿងស្លាកលេខ ពោធិ៍សាត់ 3A-1411 និងស្លាកលេខ ព្រះសីហនុ 3A-6430, ឈើប្រហែល១០គីប ប្រហែល៣ពាន់ដុល្លារ និងលុយធ្វើ office កន្លែងបើកលក់គ្រឿងសំណង់ អស់ប្រហែល ៦000$។ ចំពោះបំណុលរួមមានដូចជា៖ ជំពាក់ធនាគារអេស៊ីលីដាចំនួន ៨៤000$ , បំណុលចំនួន១៣000$ ជំពាក់ថ្លៃគ្រឿងសំណង់, បំណុលចំនួន ១៤៥0$ ជំពាក់ថ្លៃជាងជួសជុលឡានធំ, បំណុលចំនួន ៩៥0$ និងបំណុលតុងទីនចំនួន ៧៨00$។

ចុងចម្លើយ [redacted] ឈុនឡុង បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំឯកភាពក្នុងការប្តឹងសុំលែងលះរបស់ដើមចោទ, ឯកភាពទទួលទ្រព្យសម្បត្តិរួម និងទទួលខុសត្រូវបំណុលទាំងអស់តាមការស្នើសុំរបស់ដើមចោទ ក៏ប៉ុន្តែចំពោះអំណាចមេបាដែលដើមចោទស្នើសុំនោះគឺខ្ញុំមិនឯកភាពក្នុងការប្រគល់អំណាចមេបានេះបានទេ គឺខ្ញុំសុំសិទ្ធិគ្រប់គ្រងដែរ ព្រោះខ្ញុំមានលទ្ធភាពចិញ្ចឹមកូន។ ចំពោះរឿងការងារគឺអ្នកណាក៏ត្រូវតែធ្វើការដែរ ដើម្បីរកចំណូលចិញ្ចឹមកូន។ ស្នើសុំអោយតុលាការពិនិត្យលើប្រាក់ចំណូលរបស់ខ្ញុំ និងគាត់។

មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] មួយស៊ាង បានធ្វើសេចក្តីថ្លែងការណ៍ថា កូនក្តីខ្ញុំជាម្តាយរបស់កូន បានពរពោះកូន៩ខែ១០ថ្ងៃ ឆ្លងកាត់ទុកលំបាកច្រើន នៅពេលបង្កើតកូនគាត់មានការឈឺចាប់ខ្លាំង និងចំណាយឈាមទាំងថ្លុកៗ គាត់ជាម្តាយមានការថែទាំកូនបានល្អ គ្រប់ពេលវេលា ម្យ៉ាងទៀតកូននៅតូច



Scanned with CamScanner

គឺប្រាកដជាត្រូវការម្តាយជាងឪពុកហើយ ឪពុកទៅធ្វើការនៅក្រៅដូច្នេះមិនសូវមានពេលវេលាច្រើនដើម្បីមើលថែកូនទេ ដូច្នេះក្នុងនាមខ្ញុំជាមេធាវី ស្នើសុំអោយតុលាការសម្រេចអោយកូនក្តីខ្ញុំមានសិទ្ធិអំណាចមេបាលើកូនម្នាក់នេះដើម្បីមើលថែរក្សាផង។ រយះពេលតាំងពីខែមីនា ឆ្នាំ២០២៣ មានរយៈពេល៦ខែហើយដែលកូនក្តីខ្ញុំមិនបានជួបមុខកូន ហើយកូនក្តីខ្ញុំបានទៅមើលកូនដែរ តែមានការគម្រាមកំហែងផ្សេងៗ ការជួបប្រាស្រ័យទាក់ទងគឺលំបាកមែនទែន ដូច្នេះបើប្រគល់អំណាចមេបាទៅអោយចុងចម្លើយគឺរឹតតែលំបាកដល់កូនក្តីខ្ញុំ។ ចំពោះអាហារកិច្ចចិញ្ចឹមកូនគឺឪពុកម្តាយមានកាតព្វកិច្ចរួមគ្នា។

មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ឈុនឡុង បានធ្វើសេចក្តីថ្លែងការណ៍ថា កូនក្តីខ្ញុំទទួលខុសត្រូវបំណុលទាំងស្រុងក៏ជាបន្ទុកហើយ ដូច្នេះកូនក្តីខ្ញុំនៅតែស្នើសុំសិទ្ធិអំណាចមេបាដដែល កូនក្តីខ្ញុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកូន ដោយគិតពីឧត្តមប្រយោជន៍កូនជាធំ ទាំងការអប់រំ សុខភាព និងអនាគតដ៏ភ្លឺស្វាងរបស់កូន។ ខ្ញុំទទួលស្គាល់នៅពេលសហភាតាអះអាងថា ម្តាយជាអ្នកពរពោះ ក៏ប៉ុន្តែកូនក្តីខ្ញុំមិនមែនមិនអោយគាត់មកជួបជុំ ឬមកលេងកូននោះទេ។ កូនក្តីខ្ញុំថែមទាំងមានជួលអ្នកមើលថែម្នាក់មកតាមមើលថែកូនគាត់នៅសាលាទៀត។ ក្រោមការមើលថែរបស់កូនក្តីខ្ញុំគឺក្មេងមានកាយសម្បទារឹងមាំទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្ត។ ស្នើសុំអោយតុលាការសម្រេចដោយឆន្ទានុសិទ្ធិ ដោយយកប្រយោជន៍ក្មេងជាធំ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរគូភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១- ពាក្យបណ្តឹងចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ [redacted] មួយស៊ាង ធ្វើឡើងត្រឹមត្រូវទៅតាមទម្រង់ និងគតិច្បាប់ដែលអាចឱ្យតុលាការលើកយកមកធ្វើការវិនិច្ឆ័យ និងសម្រេចដល់អង្គសេចក្តីបាន។

២- គូភាគីពិតជាប្តីប្រពន្ធ មានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ពិតប្រាកដមែន តែដោយសារការរស់នៅពុំចុះសម្រុងនឹងគ្នា ហើយអស់មនោសញ្ចេតនាពីគ្នា ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាននោះ តុលាការយល់ឃើញថាដើមចោទមានមូលហេតុនៃការលែងលះគ្រប់គ្រាន់ស្របតាមមាត្រា ៩៧៨នៃក្រមរដ្ឋប្បវេណី គប្បីតុលាការពិនិត្យនិងសម្រេចតាមការទាមទាររបស់ដើមចោទ។

៣- ក្នុងអំឡុងពេលរស់នៅជាមួយគ្នាជាប្តី-ប្រពន្ធ គូភាគីបានអះអាងថាកូន០១នាក់ឈ្មោះ [redacted] ស៊ូលីន ភេទស្រី កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ដោយដើមចោទឈ្មោះ [redacted] មួយស៊ាង សុំសិទ្ធិអំណាចមេបាលើកូនស្រីម្នាក់នេះ ក៏ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ឈុនឡុង មិនឯកភាពក្នុងការប្រគល់សិទ្ធិអំណាចមេបានេះទេ ដោយចុងចម្លើយស្នើសុំសិទ្ធិអំណាចមេបាលើកូនស្រីម្នាក់នេះដែរ។

តាមមាត្រា ១០៣៧នៃក្រមរដ្ឋប្បវេណីបានចែងថា បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុកឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ ក៏ប៉ុន្តែបើការពិភាក្សារបស់ឪពុកម្តាយអំពីអំណាចមេបាពុំបានសម្រេចទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ។

៤- យោងតាមការអះអាងរបស់គូភាគី ក៏ដូចជាការពិនិត្យឯកសារដែលជាភស្តុតាងទាំងអស់ របស់គូភាគីដែលមានក្នុងសំណុំរឿង តុលាការពិចារណាឃើញថា ទាំងដើមចោទ និងចុងចម្លើយ សុទ្ធតែមានឆន្ទៈ និងទឹកចិត្តជាឪពុកម្តាយក្នុងការចង់បានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ស៊ូលីន នោះដូចគ្នា ក៏ប៉ុន្តែយោងទៅតាមភាពជាក់ស្តែងនៅក្នុងសង្គម



Scanned with CamScanner

បច្ចុប្បន្ន កូនឈ្មោះ [redacted] ស៊ូលីន ជាកូនស្រី ដែលមានអាយុទើបជិត ៤ឆ្នាំតែប៉ុណ្ណោះ ដែលពិតជាត្រូវការ ការចិញ្ចឹមបីបាច់ និងមើលថែយ៉ាងជិតស្និតពីម្តាយដែលជាស្រីដូចគ្នា លើសពីនេះទៀតចុងចម្លើយឈ្មោះ [redacted] ឈុនឡុង ដែលជាឪពុកគឺជាមន្រ្តីរាជការដែលត្រូវមានកាតព្វកិច្ចច្រើនត្រូវបំពេញ អាចជាហេតុពុំមានពេលគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់និងមើលថែយ៉ាងជិតស្និតជាមួយកូនបានច្រើនជាងខាងដើមចោទដែលម្តាយនោះទេ ដូច្នេះដោយផ្អែកទៅលើឧត្តមប្រយោជន៍កុមារជាធំ គប្បីតុលាការសម្រេចដោយឆន្ទានុសិទ្ធិក្នុងការកំណត់យកដើមចោទឈ្មោះ [redacted] មួយស៊ាង ដែលជាម្តាយជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ស៊ូលីន នេះ ស្របតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៥- ភាគីចុងចម្លើយឈ្មោះ [redacted] ឈុនឡុង ដែលមិនមានសិទ្ធិអំណាចមេបា មានសិទ្ធចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានសិទ្ធិអំណាចមេបា ត្រូវបង្ករលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀតក្នុងការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ស្របតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៦- ដើមចោទឈ្មោះ [redacted] មួយស៊ាង ប្តឹងសុំអាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ៤០០០០០៛ (សែសិបម៉ឺនរៀល) ក្នុង១ខែ ជារៀងរាល់ខែ រហូតដល់កូនមានវ័យនីតិភាព តុលាការយល់ឃើញថា កាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនគឺជាកាតព្វកិច្ចសាមគ្គីរបស់ឪពុកនិងម្តាយ លើសពីនេះទៀតទៅតាមការពិនិត្យទៅលើមុខរបរជាមន្ត្រីរាជការរបស់ភាគីចុងចម្លើយ ឃើញថា មានភាពសមល្មមទៅនិងការស្នើសុំរបស់ភាគីដើមចោទ ដូច្នេះគប្បីតុលាការសម្រេចតាមការស្នើសុំរបស់ភាគីដើមចោទ។

៧- តាមសេចក្តីថ្លែងការណ៍របស់គូភាគីនាពេលទាញហេតុផលដោយផ្ទាល់មាត់ ក៏ដូចជាភស្តុតាងមួយចំនួនដែលគូភាគីបានដាក់ជូនតុលាការពិនិត្យឃើញថា គូភាគីពិតជាមានទ្រព្យសម្បត្តិរួម និងបំណុលរួម ដែលរួមមាន៖ ផ្ទះលំនៅដ្ឋាន១ល្វែង ទំហំ ១១៤១ ម៉ែត្រការ៉េ ស្ថិតនៅភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់, ផ្ទះលំនៅដ្ឋាន១ល្វែងទំហំ៥៩ម៉ែត្រការ៉េ ស្ថិតនៅគីឡូលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ តម្លៃប្រហែល ៤០៨២៨$ (បួនម៉ឺនប្រាំបីរយម្ភៃប្រាំបីដុល្លារអាមេរិក), សម្ភារៈសំណង់សម្រាប់លក់មានតម្លៃសរុបប្រហែល៣ម៉ឺនដុល្លារអាមេរិក, រថយន្ត Pick Up ពីរបាំងម៉ាក Nissan Navara ផលិតឆ្នាំ២០១៩ ស្លាកលេខ កម្ពុជា LCL.1993 ០១គ្រឿង, រថយន្តធុនធំសម្រាប់ដឹកទំនិញចំនួន២គ្រឿងស្លាកលេខ ពោធិ៍សាត់ 3A-1411 និងស្លាកលេខ ព្រះសីហនុ 3A-6430, ឈើប្រហែល១០គីប ប្រហែល៣ពាន់ដុល្លារ និងលុយធ្វើ office កន្លែងបើកលក់គ្រឿងសំណង់ អស់ប្រហែល ៦០០០$, ជំពាក់ធនាគារអេស៊ីលីដាចំនួន ៨៥០០០$ , បំណុលចំនួន១៣០០០$ ជំពាក់ថ្លៃគ្រឿងសំណង់, បំណុលចំនួន ១៤៥០$ ជំពាក់ថ្លៃជាងជួសជុលឡានធំ, បំណុលចំនួន៩៥០$ និងបំណុលតុងទីនចំនួន ៧៨០០$ ពិតប្រាកដមែន។

ក៏ប៉ុន្តែក្រោយការពិភាក្សាគ្នារួចមក ភាគីដើមចោទឯកភាពក្នុងការប្រគល់ទ្រព្យសម្បត្តិរួម និងបំណុលរួមទាំងអស់ដែលបានរៀបរាប់ខាងលើនេះទៅអោយភាគីចុងចម្លើយជាអ្នកទទួលខុសត្រូវទាំងអស់ ហើយភាគីចុងចម្លើយក៏ឯកភាពក្នុងការទទួលខុសត្រូវផងដែរ ហេតុដូច្នេះតុលាការគប្បីសម្រេចនិងពិចារណាតាមការពិភាក្សារបស់គូភាគី ស្របតាមបញ្ញត្តិមាត្រា ៩៨០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ដែលបានចែងថា ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

៨- ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។



Scanned with CamScanner

## សេចក្ដីសម្រេចបញ្ចប់

១/-ឱ្យដើមចោទឈ្មោះ [redacted] មួយស៊ាង និងចុងចម្លើយឈ្មោះ [redacted] ឈុនឡុង លែងលះគ្នាតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

២/-កំណត់យកដើមចោទឈ្មោះ [redacted] មួយស៊ាង ជាអ្នកមានអំណាចមេបាលើកូន០១នាក់ ឈ្មោះ [redacted] ស៊ូលីន ភេទស្រី កើតថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៣/-ភាគីចុងចម្លើយឈ្មោះ [redacted] ឈុនឡុង ដែលមិនមានសិទ្ធិអំណាចមេបា មានសិទ្ធចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានសិទ្ធិអំណាចមេបា ត្រូវបង្ករលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀតក្នុងការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ស្របតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៤/- ភាគីចុងចម្លើយឈ្មោះ [redacted] ឈុនឡុង ត្រូវបង់អាហារកិច្ចចិញ្ចឹមបីបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ៤០០០០០៛ (សែសិបម៉ឺនរៀល) ក្នុង១ខែ រហូតដល់កូនស្រីឈ្មោះ [redacted] ស៊ូលីន ដល់វ័យនីតិភាព។

៥/- ប្រគល់ទ្រព្យសម្បត្តិរួម និងបំណុលរួមទាំងអស់ (ដូចមានក្នុងចំណុចទី៧ នៃសំអាងហេតុ) ទៅអោយចុងចម្លើយឈ្មោះ[redacted]ឈុនឡុង ជាអ្នកទទួលខុសត្រូវបន្តទាំងអស់ តាមការពិភាក្សារបស់គូភាគី។

៦/- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ។

បើកផ្លូវ ប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ពោធិ៍សាត់,ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍៧រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ពោធិ៍សាត់,ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានសាលាដំបូងខេត្ត**

[redacted]



Scanned with CamScanner